**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

លេខៈ ៦៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ក្រមសីលធម៌នៃអ្នកសិល្បៈ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណង៖

- លើកកម្ពស់ការថែរក្សា ការពារសិល្បៈ វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី និងអត្តសញ្ញាណជាតិឱ្យបានគង់វង្ស ដើម្បីលើកកម្ពស់កិត្យានុភាពជាតិនិងការអភិវឌ្ឍប្រកបដោយចីរភាព
- ទប់ស្កាត់ផលប៉ះពាល់ដែលមានលក្ខណៈអវិជ្ជមានចំពោះសិល្បៈប្រពៃណីជាតិ។



ទូរស័ព្ទ / ទូរសារ: 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72

**ប្រការ២ .-**

ប្រកាសនេះមានគោលដៅ៖

- លើកកម្ពស់ឥរិយាបថ អត្តចរិត វោហារសព្ទ សំណេរ និងប្រឌិតញ្ញាណរបស់អ្នកសិល្បៈស្របតាមវប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីដ៏ល្អផុរផង់របស់ជាតិ
- លើកកម្ពស់សីលធម៌ គុណធម៌ សច្ចធម៌ និងសេចក្តីថ្លៃថ្នូរនៃអ្នកប្រកបមុខរបរពាក់ព័ន្ធនឹងវិស័យសិល្បៈវប្បធម៌ ដើម្បីឧត្តមភាពបុគ្គល សង្គម និងដើម្បីជាគំរូដ៏ល្អប្រសើរសម្រាប់អ្នកបន្តវេន
- លើកកម្ពស់ការប្រើប្រាស់សក្តានុពលវប្បធម៌ដើម្បីការអប់រំនិងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

**ប្រការ៣ .-**

ប្រកាសនេះ មានវិសាលភាពគ្របដណ្តប់ទៅលើជនទាំងឡាយណា ដែលបាននិងកំពុងធ្វើសកម្មភាពពាក់ព័ន្ធនឹងវិស័យសិល្បៈវប្បធម៌។

**ប្រការ៤ .-**

វាក្យសព្ទដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- ក្រមសីលធម៌នៃអ្នកសិល្បៈ សំដៅដល់បណ្តុំវិធាន ឬ វិន័យសម្រាប់ចង្អុលបង្ហាញឱ្យអ្នកដែលបាននិងកំពុងធ្វើសកម្មភាពពាក់ព័ន្ធនឹងវិស័យសិល្បៈវប្បធម៌ឱ្យប្រតិបត្តិតែអំពើល្អ វៀរចាកអំពើអាក្រក់ដើម្បីទទួលបានកិត្តិយសនិងសេចក្តីថ្លៃថ្នូរ
- គុណធម៌ សំដៅដល់កិរិយានៃការប្រព្រឹត្តទៅប្រកបដោយសេចក្តីល្អ បរិសុទ្ធ អាណិត ប្រណី និងជាកិរិយាដែលចម្រើនឡើងដល់ការតបស្នងចំពោះអ្នកដែលមានឧបការគុណមកលើខ្លួន
- ប្រឌិតញ្ញាណ សំដៅដល់គំនិតច្នៃប្រឌិតថ្មីៗដែលទាក់ទងនឹងវិស័យសិល្បៈវប្បធម៌
- មនសិការ សំដៅដល់ការកំណត់ទុកនៅក្នុងចិត្ត ដំណើរយកចិត្តទុកដាក់
- វប្បធម៌ សំដៅដល់ទំនៀមទម្លាប់ប្រពៃណី ជំនឿសាសនា ផ្នត់គំនិត បច្ចេកវិទ្យា និងឥរិយាបថនៃសង្គមមនុស្ស ឬ ជាតិសាសន៍មួយ
- វប្បធម៌អវិជ្ជមាន សំដៅដល់អំពើដែលពាក់ព័ន្ធនឹងវិស័យវប្បធម៌ទាំងឡាយណាដែលអាចនឹងនាំឱ្យមានល្បសនកម្មដល់វប្បធម៌ប្រពៃណីដ៏ល្អរបស់ជាតិ
- វោហារសព្ទ សំដៅដល់ពាក្យសម្តី ថ្វីមាត់ដែលបានបន្លឺឡើង
- សច្ចធម៌ សំដៅដល់កិរិយានៃការប្រព្រឹត្តទៅប្រកបដោយសេចក្តីពិតនិងទៀងត្រង់
- សីលធម៌ សំដៅដល់កិរិយានៃការប្រព្រឹត្តទៅដោយវៀរចាកនូវអំពើអាក្រក់ ប្រកាន់យកតែអំពើល្អទាំងកាយ វាចា និងចិត្ត
- សុចរិតធម៌ សំដៅដល់ការប្រព្រឹត្តអំពើល្អទាំងកាយ វាចា និងចិត្ត ( កាយសុចរិត វចីសុចរិត មនោសុចរិត )
- អ្នកសិល្បៈ សំដៅដល់ជនដែលមានចំណេះដឹងនិងបានធ្វើសកម្មភាពពាក់ព័ន្ធទៅនឹងផ្នែកតូ្យតន្ត្រី ចម្រៀង រាំ របាំ វោហារសព្ទ និងផលិតផលសិល្បៈវប្បធម៌
- អ្នកបង្កើតស្នាដៃ សំដៅដល់អ្នកនិពន្ធ ឬ ជនដែលបានបង្កើតតូ្យតន្ត្រី របាំ ចម្រៀង វោហារកោសល្យ ប្រឌិតញ្ញាណ និងផលិតផលសិល្បៈវប្បធម៌ ✓



គេទម្លាក់ព័ត៌មានសាធារណៈ - https://t.me/oa_channel

អ្នកសម្តែង សំដៅដល់អ្នកសិល្បៈ អ្នករបាំ អ្នកតន្ត្រី អ្នកចម្រៀង អ្នកបញ្ចេញកាយវិការ និងអ្នកប្រើប្រាស់វោហារសព្ទ។

## ជំពូកទី២

## ភារកិច្ចទូទៅនៃអ្នកសិល្បៈ

**ប្រការ៥ .-**

អ្នកសិល្បៈទាំងអស់៖

- ត្រូវមានភក្តីភាពចំពោះ ជាតិ សាសនា និងព្រះមហាក្សត្រ
- ត្រូវប្រកាន់ខ្ជាប់នូវស្មារតីសាមគ្គីភាព ឯកភាពជាតិខ្ពស់ រស់នៅក្នុងភាពជាបងប្អូន ដោយចេះជួយគ្នាទៅវិញទៅមកស្របតាមវប្បធម៌ ប្រពៃណីដ៏ថ្លៃថ្លានៃដូនតាយើង
- ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍សីលធម៌ គុណធម៌ សច្ចធម៌ ទាំងសំណេរ ទាំងការប្រើប្រាស់ពាក្យពេចន៍ កាយវិការ សកម្មភាព ឥរិយាបថ ការស្លៀកពាក់ ដោយរក្សាឱ្យបាននូវភាពថ្លៃថ្នូរ ដើម្បីរួមចំណែកលើកកម្ពស់សីលធម៌សង្គមនិងកិត្យានុភាពជាតិ
- ត្រូវគោរពស្រឡាញ់ការងារ ចំណេះ ជំនាញ ទាំងតម្លៃពិតខាងស្មារតីនិងបច្ចេកទេស
- ត្រូវផ្ទេរចំណេះ ជំនាញ ដែលខ្លួនមានឱ្យបានដល់អ្នកបន្តវេនជំនាន់ក្រោយ
- ត្រូវមានមនសិការចូលរួមអនុវត្តឱ្យបានសម្រេចនូវ "គោលនយោបាយជាតិស្តីពីវិស័យវប្បធម៌" និងការលើកស្ទួយកិច្ចការសង្គម
- ត្រូវប្រកាន់ខ្ជាប់នូវមនសិការជាអ្នកបន្តវេនមរតកវប្បធម៌ដ៏ល្អផ្ទុរផង់របស់បុព្វបុរសយើង និង ជាគំរូដ៏ប្រពៃថ្លៃថ្លាដល់អ្នកបន្តវេនជំនាន់ក្រោយៗទៀត
- ត្រូវចៀសវាងឱ្យបានដាច់ខាតនូវគ្រប់សកម្មភាពនិងឥរិយាបថទាំងឡាយណា ដែលមានផលប៉ះពាល់ជាលក្ខណៈអវិជ្ជមានដល់វប្បធម៌ ប្រពៃណី និងកិត្យានុភាពជាតិ
- ត្រូវចៀសវាងឱ្យបាននូវប្រនិតញាណ ការសម្តែងដែលមានលក្ខណៈអុជអាល បំបែកបំបាក់ ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ និងជំនឿសាសនា។

## ជំពូកទី៣

## ភារកិច្ចនៃអ្នកបង្កើតស្នាដៃ

**ប្រការ៦ .-**

អ្នកបង្កើតស្នាដៃ៖

- ត្រូវបង្កើតស្នាដៃចេញពីសមត្ថភាពនៃប្រនិតញាណរបស់ខ្លួនដោយផ្ទាល់
- ត្រូវរក្សាឱ្យបាននូវពណ៌សម្បុរនិងអត្តសញ្ញាណជាតិ
- ត្រូវប្រមូលផ្តុំលើការអប់រំស្របតាម "គោលនយោបាយជាតិស្តីពីវិស័យវប្បធម៌" និងត្រូវគោរពឱ្យបាននូវគោលការណ៍សច្ចធម៌ គុណធម៌ និងសោភណភាពស្របតាមអត្តសញ្ញាណជាតិ
- ត្រូវបង្កប់នូវគំនិតនិងទស្សនៈល្អៗ ដែលមានគុណប្រយោជន៍ដល់ការលើកកម្ពស់ការអប់រំសីលធម៌ គុណធម៌ មនសិការស្នេហាជាតិ ស្នេហាវប្បធម៌ និងការអភិវឌ្ឍសង្គម ល.ល/

- ត្រូវប្រកាន់ខ្ជាប់នូវមនសិការចូលរួម គាំទ្រគ្រប់សកម្មភាពអប់រំនិងកិច្ចការសង្គម
- ត្រូវផ្អែកទៅលើគោលការណ៍ ឯករាជ្យភាព សុចរិតភាព សច្ចភាព និងគុណភាព
- ត្រូវចៀសវាងឱ្យបាននូវការបង្កើតស្នាដៃដែលមានលក្ខណៈអុជអាល បំបែកបំបាក់ ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ និងជំនឿសាសនា
- ត្រូវតម្កល់ស្នាដៃរបស់ខ្លួនទុកជាកេរដំណែលសម្រាប់មនុស្សជំនាន់ក្រោយ ពិសេសចងក្រងឯកសារដែលបានសិក្សាស្រាវជ្រាវរកឃើញទុកជាក្បួនតម្រា។

## ជំពូកទី៤

## ភារកិច្ចនៃអ្នកសម្តែង

**ប្រការ៧ .-**

អ្នកសម្តែង៖

- ត្រូវរក្សាឱ្យបាននូវសុជីវធម៌ សីលធម៌ ភាពថ្លៃថ្នូរ ទាំងកាយវិការ ការស្លៀកពាក់ និងវោហារសព្ទ
- ត្រូវគោរពវិន័យឱ្យបានត្រឹមត្រូវទាំងក្នុងពេលហាត់សម មុនសម្តែង ពេលកំពុងសម្តែង និងក្រោយពេលសម្តែង
- ត្រូវចៀសវាងឱ្យបាននូវអំពើទាំងឡាយណាដែលធ្វើឱ្យអាប់ឱនដល់កិត្តិយសនៃអ្នកសិល្បៈ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ
- ត្រូវចៀសវាងឱ្យបានដាច់ខាតនូវការប្រើប្រាស់កាយវិការនិងពាក្យពេចន៍ដែលមានលក្ខណៈ អាសអាភាស អសុរោះ ញុះញង់ អុជអាល និងបំបែកបំបាក់
- មិនត្រូវយកអារម្មណ៍មិនល្អពីខាងក្រៅទៅប្រើប្រាស់ក្នុងពេលសម្តែងដែលនាំឱ្យប៉ះពាល់ ឬ ខូចខាតដល់គុណភាពសម្តែងដល់កិត្តិយសសហការីរួមការងារជាមួយគ្នា និង ត្រូវថ្លឹងអារម្មណ៍ដើម្បីលើកតម្លៃទាំងបច្ចេកទេសនិងស្មារតីក្នុងការសម្តែង
- មិនត្រូវធ្វើឱ្យបាត់បង់គុណតម្លៃ ក្នុងពេលបំពេញភារកិច្ចរបស់ខ្លួនក្រោមលក្ខខណ្ឌនៃកិច្ចសន្យាណាមួយឡើយ
- មិនត្រូវយកភាពល្បីល្បាញរបស់ខ្លួនទៅគាបសង្កត់ធ្វើឱ្យខូចប្រយោជន៍ដល់អ្នកដទៃ ទោះក្នុងរូបភាពណាក៏ដោយ។

## ជំពូកទី៥

## សមាសភាពក្រុមប្រឹក្សាក្រមសីលធម៌នៃអ្នកសិល្បៈ

**ប្រការ៨ .-**

សមាសភាពក្រុមប្រឹក្សាក្រមសីលធម៌នៃអ្នកសិល្បៈមានដូចខាងក្រោម៖

| | | |
|---|---|---|
| ១- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ១រូប | ប្រធាន |
| ២- ទីប្រឹក្សាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ១រូប | អនុប្រធាន |
| ៤- អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ | | សមាជិក |

៥- អគ្គនាយកបច្ចេកទេសវប្បធម៌ សមាជិក

៦- ប្រធានសមាគមខ្សែទស្សន៍កម្ពុជា សមាជិក

៧- ប្រធានសមាគមផលិតភាពយន្តកម្ពុជា សមាជិក

៨- ប្រធានសមាគមសិល្បករខ្មែរ សមាជិក

៩- ប្រធានសមាគមពិធីករ ពិធីការិនីកម្ពុជា សមាជិក

១០- ប្រធានសមាគមអ្នកនិពន្ធខ្មែរ សមាជិក

១១- ប្រធានសមាគមមិត្តអ្នកបញ្ចូលសំឡេង សមាជិក

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អាចស្នើសុំក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់តាំងតំណាងចូលជាអនុប្រធាន ឬ ជាសមាជិកក្រុមប្រឹក្សាក្រមសីលធម៌នៃអ្នកសិល្បៈ។

ក្រុមប្រឹក្សាក្រមសីលធម៌នៃអ្នកសិល្បៈ ត្រូវមានលេខាធិការដ្ឋានមួយជាជំនួយការ។ សមាសភាពក្រុមប្រឹក្សា និងលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

## ជំពូកទី៦
## ការលើកសរសើរ និង ពិន័យបញ្ញត្តិ

**ប្រការ៩ ._**

អ្នកសិល្បៈទាំងក្នុងអាជីពនិងមហាជនដែលបានធ្វើសកម្មភាពទាក់ទងនឹងវិស័យសិល្បៈវប្បធម៌ ស្របតាមក្រមសីលធម៌នៃអ្នកសិល្បៈនេះ និង/ឬ បានចូលរួមក្នុងសកម្មភាពលើកកម្ពស់សិល្បៈ វប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីជាតិបានល្អប្រពៃ ស្របតាមគោលនយោបាយជាតិស្ដីពីវិស័យវប្បធម៌ នឹងទទួលបាននូវការសរសើរលើកទឹកចិត្តដោយការផ្តល់ជូននូវមេដាយ បណ្ណសរសើរ ឬ លិខិតសរសើរ។

**ប្រការ១០ ._**

អ្នកសិល្បៈទាំងក្នុងអាជីពនិងមហាជន ដែលបាននិងកំពុងធ្វើសកម្មភាពទាក់ទងនឹងវិស័យសិល្បៈវប្បធម៌ ហើយបានប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌នៃអ្នកសិល្បៈនេះ និង/ឬ បណ្តាលឱ្យមានព្យសនកម្មដល់សិល្បៈវប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីជាតិ នឹងត្រូវទទួលពិន័យទៅតាមស្ថានកំហុសឆ្គងដែលបានប្រព្រឹត្តមានជាអាទិ៍៖

- ណែនាំ ឬ ស្តីបន្ទោសដោយផ្ទាល់មាត់ និង/ឬ ព្រមានជាលាយលក្ខណ៍អក្សរផ្សព្វផ្សាយជាសាធារណៈ
- ផ្អាកមិនឱ្យធ្វើសកម្មភាពទាក់ទងនឹងវិស័យសិល្បៈវប្បធម៌ ក្នុងរយៈពេលណាមួយស្របតាមកំហុសឆ្គងនៃអ្នកសិល្បៈនោះបានប្រព្រឹត្ត។

**ប្រការ១១ ._**

ការសម្រេចលើកសរសើរនិងដាក់ពិន័យ៖

- ការលើកសរសើរដោយផ្ទាល់មាត់ ការផ្តល់ជូនលិខិតសរសើរ ការណែនាំ ឬ ការស្តីបន្ទោសដោយផ្ទាល់មាត់ និង/ឬ ការព្រមានជាលាយលក្ខណ៍អក្សរចំពោះអ្នកសិល្បៈ ជាសិទ្ធិសម្រេចរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

- ការលើកយោបល់ស្នើសុំផ្តល់ជូនមេដាយ បណ្ណសរសើរ ការផ្អាក និងរយៈពេលនៃការផ្អាក ដោយមិនឱ្យអ្នកសិល្បៈធ្វើសកម្មភាពទាក់ទងនឹងវិស័យសិល្បៈវប្បធម៌ ជាសិទ្ធិសម្រេចរបស់ក្រុមប្រឹក្សាក្រមសីលធម៌នៃអ្នកសិល្បៈ
- រាល់សេចក្តីសម្រេចទាំងអស់ដែលទាក់ទងនឹងការពិន័យនិងការលើកសរសើរខាងលើ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ ព្រមទាំងចម្លងចែកគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ១២ .-**

ប្រកាសលេខ១៦១ ប្រ.ក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦ ស្តីពីក្រមសីលធម៌នៃអ្នកសិល្បៈ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣ .-**

អ្នកសិល្បៈគ្រប់រូបដាច់ខាតទាំងក្នុងអាជីពនិងមហាជនមានកាតព្វកិច្ចត្រូវគោរពតាមក្រមសីលធម៌នៃអ្នកសិល្បៈនេះ។

**ប្រការ១៤ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ អគ្គនាយក ប្រធានអង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.ចន្ទ..១៣កើត..ខែ.ពិសាខ.....ឆ្នាំ.រោង....ឆស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..២០.....ខែ..ឧសភា..ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

បណ្ឌិតសភាចារ្យ **ភឿង សកុណា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ប្រធានសមាគមទូរទស្សន៍កម្ពុជា
- ប្រធានសមាគមផលិតភាពយន្តកម្ពុជា
- ប្រធានសមាគមសិល្បករខ្មែរ
- ប្រធានសមាគមពិធីករ តិធីការិនីកម្ពុជា
  ប្រធានសមាគមអ្នកនិពន្ធខ្មែរ
- ប្រធានសមាគមមិត្តអ្នកបញ្ចូលសំឡេង
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ